# ព្រះពុទ្ធ ២៨ ព្រះអង្គ

**នមោ មេ សព្វពុទ្ធានំគុណសាគរានំ មហេសិនំ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គដែលបានត្រាស់ រួចមកហើយ ព្រះអង្គស្វែងរកគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះគឺ)

១-**តណ្ហង្ករោ មហាវីរោ** -ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ

២-**មេធង្ករោ មហាយសោ** -ព្រះមេធង្ករ ព្រះអង្គមានយសធំ

៣-**សរណង្ករោលោកហិតោ** -ព្រះសរណង្ករ ព្រះអង្គធ្វើជាប្រយោជន៍ដល់សត្វលោក ។

៤-**ទីបង្ករោ ជុតិន្ធរោ** - ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង

៥-**កោណ្ឌញ្ញោ ជនបាមោក្ខោ** - ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន ។

៦-**មង្គលោ បុរិសាសភោ** -ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ

៧-**សុមនោ សុមនោ ធីរោ** -ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ

៨-**រេវតោ រតិវឌ្ឍនោ** -ព្រះរេវត ព្រះអង្គញាំងសេចក្តីត្រេកអរអោយចំរើន ។

៩_**សោភិតោ គុណសម្បន្នោ** _ ព្រះសោភិត ព្រះអង្គបរិបូណដោយព្រះគុណ ។

១០_**អនោមទស្សី ជនុត្តមោ** _ ព្រះអនោម ទស្សីព្រះអង្គឧត្តមជាងពពួកជន ។

១១_**បទុមោ លោកបជ្ជោតោ** _ ព្រះបទុម ព្រះអង្គញាំងលោក ឱ្យភ្លឺស្វាង

១២_**នារទោ វរសារថី** _ ព្រះនារទ ព្រះអង្គដូចសារថីដ៏ប្រសើរ

១៣_**បទុមុត្តរោ សត្តសារោ** _ ព្រះបទុមុត្តរ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ ។

១៤_**សុមេធោ អប្បដិបុគ្គលោ** _ ព្រះសុមេធ ព្រះអង្គរកបុគ្គប្រៀបដូចគ្មាន ។

១៥_**សុជាតោ សព្វលោកគ្គោ** _ ព្រះសុជាត ព្រះអង្គប្រសើរជាងសត្វលោកទាំងពួង ។

១៦_**បិយទស្សី នរាសភោ** _ ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន

១៧_**អត្ថទស្សី ការុណិកោ** _ ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា

១៨_**ធម្មទស្សី តមោនុទោ** _ ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត

១៩.**សិទ្ធត្ថោ អសមោលោកេ** - ព្រះសិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក ។

២០.**តិស្សោ ច វទតំ វរោ** - ព្រះតិស្ស ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ ។

២១.**ផុស្សោ ច វរទោ ពុទ្ធោ** - ព្រះពុទ្ធ ទ្រង់ព្រះនាមផុស្ស ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ ។

២២.**វិបស្សី ច អនូបមោ** - ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ ។

២៣.**សិខី សព្វហិតោ សត្ថា** - ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅធ្វើអោយជាប្រយោជន៍ ដល់សត្វទាំងពួង ។

២៤.**វេស្សភូ សុខទាយកោ**- ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ។

២៥.**កកុសន្ធោ សត្ថវាហោ** - ព្រះកកុសន្ធ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺ កិលេស ។

២៦.**កោនាគមនោ រណញ្ជហោ** - ព្រះកោនាគមន ព្រះអង្គបំបាត់ បង់នូវសត្រូវ គឺកិលេស ។

**២៧-កស្សបោ សិរិសម្បន្នោ** - ព្រះកស្សប ព្រះអង្គបរិបូណ៌ដោយសិរី

**២៨-គោតមោ សក្យបុង្គវោ** - ព្រះគោតម ព្រះអង្គប្រសើរចម្បង ជាងពួកសក្យរាជ ។

------------------------

# ឯតទគ្គ-អសីតិមហាសាវក

*សុត្តបិដកអង្គុត្តរនិកាយឯកទុកនិបាតបឋមភាគភាគ៤០,ទំព័រ៥៣*

ឯតទគ្គំ ភិក្ខវេ មម សាវកានំ  ភិក្ខូនំ រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ។ មហាបញ្ញានំ យទិទំ សារីបុត្តោ ។ ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ។ ធូតវាទានំ យទិទំ មហាកស្សបោ ។ ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយ បុត្តោ ។មញ្ជុស្សរានំ យទិទំ លកុណ្ដក ភទ្ទិយោ ។ សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ ។ ធម្មកថិកានំ យទិទំបុណ្ណោ មន្តានីបុត្តោ ។ សង្ខិត្តេន ភាសិតស្សវិត្ថា រេនអត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ ។

(វគ្គោ បឋមោ)

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ ។ ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។ បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ អរណាវិហារីនំ យទិទំ សុភូតិ ។ទក្ខិណេយ្យានំ នយទិទំ សុភូតិ អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ឈាយីនំ យទិទំ កង្ខារេវតោ ។ អារទ្ធវីរិយានំ យទិទំ សោណោ កោលិវិសោ។ កល្យាណវាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ ។ លាភីនំ យទិទំសីវលី ។ សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ ។

(វគ្គោ ទុតិយោ)

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សិក្ខាកាមានំ យទិទំ រាហុលោ ។ សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ ។ បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។ បដិភាណវន្តានំ យទិទំ វង្គីសោ ។ សមន្តបាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ។ សេនាសនបញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ។ ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។ ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។ ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។ បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោតិ ។

(វគ្គោ តតិយោ)

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ ។ សតិមន្តានំ យទិទំ អានន្ទោ ។ គតិមន្តានំ យទិទំ អានន្ទោ ។ ធិតិមន្តានំ យទិទំ អានន្ទោ ឧបដ្ឋាកានំ យទិទំ អានន្ទោ ។ មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។ កុលប្បសាទកានំ យទិទំ កាឡុទាយិ ។ អប្បាពាធានំ យទិទំ ពក្កុលោ ។ បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ ។ វិនយធរានំ យទិទំ ឧបាលិ ។ ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។ ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។ ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ។ តេជោធាតុ កុសលានំ យទិទំ សាគតោ ។ បដិភាណេយ្យកានំ យទិទំ រាធោ ។ លូខចីវរធរានំ យទិទំ មោឃរាជាតិ។

(វគ្គោ ចតុត្ថោ)

ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ រត្តញ្ញូនំ យទិទំ មហាប ជាបតី គោតមី ។ មហាបញ្ញានំ យទិទំ ខេមា ។ ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា ។វិនយធរានំ យទិទំ បដាចារា ។ ធម្មកថិកានំ យទិទំ ធម្មទិន្នា ។ ឈាយិនីនំ យទិទំ នន្ទា។ អារទ្ធវីរិយានំ យទិទំ សោណា ទិព្វចក្ខុកានំ យទិទំ សកុលា ។ ខិប្បាភិញ្ញានំ យទិទំ ភទ្ទាកុណ្ឌលកេសា ។ បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទាកបិលានី ។ មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា ។ លូខចីវរធរានំ យទិទំ កិសាគោតមី ។ សទ្ធាធិមុត្តានំ យទិទំ សិគាលមាតាតិ ។

(វគ្គោ បញ្ចមោ)

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា ។ ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។ ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ ។ ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោអាឡវកោ ។ បណីតទាយកានំ យទិទំ មហានាមោ សក្កោ ។ មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ។ សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ។ អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។ បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។ វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ។

(វគ្គោ ឆដ្ឋោ)

ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា ។ ទាយិកានំ យទិទំ វិសាខា មិគារមាតា ។ ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។ មេត្តាវិហារីនំ យទិទំ សមាវតី ។ ឈាយីនំ យទិទំ ឧត្តរា នន្ទមាតា ។ បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា ។ គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា ។ អវេច្ចប្បសន្នានំ យទិទំ កាតិយានី ។ វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី ។ អនុស្សវប្បសន្នានំ យទិទំ កាលីឧបាសិកា កុររឃរិកាតិ។

(វគ្គោ សត្តមោ)

# ព្រះធម្មចក្កប្បវត្តនសូត្រ

ឯវម្មេ សុតំ សូត្រនេះ ( ឈ្មោះធម្មចក្កប្បវត្តនសូត្រ ) គឺ ខ្ញុំ ( ឈ្មោះអានន្ទ ) បានស្តាប់មកហើយ យ៉ាងនេះថា :

ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃ ឥសិបតនមិគទាយវ័នជិតក្រុងពារាណសី ។

តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ ព្រះដ៏មាន ព្រះភាគ ទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុទាំងឡាយក្នុងទីនោះ ឯង (ឱ្យតាំងចិត្តស្តាប់នូវភាសិតនេះថា ) :

ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ម្នាលភិក្ខុទាំងឡាយ អន្តធម៌គឺធម៌ជាផ្លូវប្រតិបត្តិ អមខាងដ៏លាមកអាក្រក់ ទាំងឡាយពីរ ប្រការនេះបព្វជិតមិនគួរសេពគប់ គឺថាមិនគួរ ប្រព្រឹត្តឡើយ ។

កតមេ ទ្វេ អន្តធម៌ទាំងឡាយ ពីរយ៉ាងនោះដូចម្តេច ?

យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ធម៌ណា

ដែលប្រកបខ្លួន ឱ្យជាប់ជំពាក់ដោយកាម ក្នុងកាមទាំងឡាយ

ហីនោ ជាធម៌ថោកទាប

គម្មោ ជាធម៌របស់អ្នកស្រុក

បោថុជ្ជនិកោ ជាធម៌របស់បុថុជ្ជន

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ

យោ ចាយំ អត្តកិលមថានុយោគោ ធម៌ណាដែលប្រកប

សេចក្តីលំបាកដល់ខ្លួន

ទុក្ខោ ជាហេតុនាំឱ្យលំបាកកាយទទេៗ

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ

ឯតេ តេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ

**និព្វានាយ សំវត្តតិ** ម្នាល ភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាល មិនលាយច្រឡំ ដោយអន្តធម៌ទាំងឡាយ ពីរយ៉ាងនេះឯង ដែលតថាគតបាន ត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ (ភ្នែក គឺប្រាជ្ញា) ធ្វើឱ្យ កើត សេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រំងាប់ ដើម្បី សេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។

**កតមា ច សា ភិក្ខវេ មជ្ឈិមាបដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រំងាប់ ដើម្បីសេចក្តី ដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ នោះ តើដូចម្តេច ?

**អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ** អដ្ឋង្គិកមគ្គ គឺធម៌ដូច ជាផ្លូវ មានអង្គ ៨ ដ៏ប្រសើរនេះឯង ( ហៅថា សេចក្តីប្រតិបត្តិ ជាកណ្តាល )

**សេយ្យថីទំ** អដ្ឋង្គិកមគ្គនោះ ដូចម្តេចខ្លះ ?

**សម្មាទិដ្ឋិ** ប្រាជ្ញាយល់ឃើញត្រូវ

សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ

សម្មាវាចា សម្តីត្រូវ

សម្មាកម្មន្តោ ការងារត្រូវ

សម្មាអាជីវោ កិរិយាចិញ្ចឹមជីវិតត្រូវ

សម្មាវាយាមោ ព្យាយាមត្រូវ

សម្មាសតិ សេចក្តីរឭកត្រូវ

សម្មាសមាធិ កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ

**អយំ ខោ សា ភិក្ខវេ មជ្ឈិមាបដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គ នេះឯង ដែលហៅថា សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគត បានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិ ធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បី សេចក្តីស្ងប់រំងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹង ដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។

**ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ( ព្យាធិបិ ទុក្ខោ ) មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោម~ នស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា** ម្នាលភិក្ខុទាំងឡាយ ជាតិ គឺកិរិយាកកើត នៃខន្ធ ជាហេតុនាំមកនូវទុក្ខ ជរា គឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ (ព្យាធិ គឺជំងឺតម្កាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ ) មរណៈ គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជា ហេតុនាំមកនូវទុក្ខ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាប្រកបដោយសត្វ និងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាព្រាត់ប្រាស ចាកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កាលបើចង់បាននូវវត្ថុណាមួយហើយ មិនបាន នូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ ឧបាទានក្ខន្ធ ទាំងឡាយ ៥ ដែលតថាគតសម្តែងហើយ ដោយ បំប្រួញ ក៏ជាហេតុ នាំមកនូវទុក្ខ កងទុក្ខមានជាតិជាដើមនេះ ឈ្មោះថា ទុក្ខអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែង នូវភពថ្មី ប្រកបដោយតម្រេក ដោយអំណាច នៃសេចក្តីត្រេកត្រអាល មាន កិរិយារីករាយក្នុង អារម្មណ៍នោះៗ ជាប្រក្រតីតណ្ហានោះ ដូចម្តេចខ្លះ ?

( តណ្ហា នោះ ) គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហាទាំង ៣ នេះ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហា នោះ ដោយអរិយមគ្គមិនឱ្យមានសេសសល់ កិរិយាលះបង់នូវ តណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុត ចាកតណ្ហានោះ កិរិយាមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហា ដោយអរិយមគ្គមិនឱ្យមានសេសសល់ ជាដើមនេះឯង ឈ្មោះថា ទុក្ខនិរោធអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មា សង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គដ៏ប្រសើរ នេះឯង ដូចម្ដេចខ្លះ ? គឺប្រាជ្ញាយល់ឃើញត្រូវ សេចក្ដីត្រិះរិះត្រូវ សម្ដីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្ដីរឭកត្រូវ កិរិយាតម្កល់ ចិត្តឱ្យនឹងត្រូវ អដ្ឋង្គិកមគ្គដ៏ប្រសើរ នេះឯង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

(កាលត្រាស់ទេសនានូវលក្ខណៈនៃអរិយសច្ច ៤ ប្រការ ដូច្នេះហើយ ទើបត្រាស់ទេសនានូវញាណទាំង ៣ ប្រការ គឺ សច្ចញ្ញាណ កិច្ចញ្ញាណ កតញ្ញាណ ឱ្យទូទៅក្នុងអរិយសច្ច ៤ តទៅទៀតថា) :

ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើត ឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮបានស្ដាប់ថា នេះជាទុក្ខអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើង ហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង គួរតែកំណត់ដឹងដោយបញ្ញា ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុ ទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង តថាគតកំណត់ដឹងបានហើយ ដូច្នេះឡើយ ។

ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ

ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខសមុទយអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង កើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខសមុទយអរិយសច្ច នេះឯង តថាគតគួរតែលះបង់ ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើង ហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ

ពន្លឺភ្លឺស្វាង កើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខសមុទយអរិយសច្ច នេះឯង តថាគតលះបង់បានហើយ ដូច្នេះឡើយ ។

ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើង ហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់ បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង កើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម

តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះ ឯង គួរតែធ្វើឱ្យជាក់ច្បាស់ ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើង ហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង កើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះ ឯង តថាគតធ្វើឱ្យជាក់ច្បាស់បានហើយ ដូច្នេះឡើយ ។

ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុ ទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម

តថាគត មិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើង ហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំង-ឡាយ ដែលពីដើម តថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង គួរតែចម្រើនឱ្យកើត ឡើង ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើត ឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែល ពីដើម តថាគត

មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធគាមិនី បដិបទាអរិយសច្ចនេះឯង តថាគត ចម្រើនឱ្យកើតបានហើយ ដូច្នេះឡើយ ។

**យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្តំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ** ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដែលដឹងច្បាស់ ឃើញ ច្បាស់តាមពិត មានបរិវដ្តៈ ៣ មានអាការ ១២ យ៉ាងនេះ ( ប្រព្រឹត្តទៅ ) ក្នុងអរិយសច្ចទាំងឡាយ ៤ នៅមិនទាន់បរិសុទ្ធ ល្អ មានដល់តថាគត អស់កាលត្រឹមណា ។

**នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ** ម្នាលភិក្ខុទាំងឡាយ តថាគត ក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀត ក្រៃលែងជាងក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាល ត្រឹមណោះនៅឡើយទេ ។

យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ ម្នាលភិក្ខុទាំងឡាយ ក៏បញ្ញាដែលដឹងច្បាស់ ឃើញ ច្បាស់តាមពិត មាន បរិវដ្ដៈ ៣ មានអាការ ១២ យ៉ាងនេះ ( ប្រព្រឹត្តទៅ ) ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ បរិសុទ្ធល្អ មានដល់តថាគត ក្នុងកាលឯណា ។

អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ម្នាលភិក្ខុទាំងឡាយ តថាគតប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្ដីដឹងឯទៀត ក្រៃលែងជាងក្នុងលោក ព្រមទាំង ទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំង សមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេព និងមនុស្ស ដ៏សេស ក្នុងកាលណោះឯង ។

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់កើតឡើងហើយ ដល់តថាគតដូច្នេះថា សេចក្ដីរួច ផុតវិសេស របស់តថាគត

មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះ ក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការ ត្រឡប់កើតទៀត ក៏មិនមានឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគ បានត្រាស់ទេសនា

ព្រះធម្មចក្កប្បវត្តនសូត្រនេះ ( ចប់ហើយ ) ។

**អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ** បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះដ៏មានព្រះភាគដោយក្រៃពេក ។

**ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ** នាកាលវេយ្យាករណ៍ គឺព្រះសូត្រដែលឥតមានគាថានេះ ដែលព្រះដ៏មានព្រះភាគ កំពុងត្រាស់ទេសនា ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី គឺរាគៈ ប្រាសចាកមន្ទិល ( គឺអកុសល ) កើតឡើងហើយ ដល់ ព្រះកោណ្ឌញ្ញៈដ៏មានអាយុថា :

**យំ ភិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ** ធម្មជាតិណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតិនោះទាំងអស់ មានកិរិយារលត់ទៅជាធម្មតា ។

**បវត្តិតេ ច ភគវតា ធម្មចក្កេ** ក៏នាកាលព្រះធម្មចក្កប្បវត្តនសូត្រ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទេសនាចប់ហើយ ។

**ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ** ភុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេង ឱ្យលាន់ឮឡើងដូច្នេះថា ចក្រ គឺធម៌នេះ ឥតមានចក្រឯណា មួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តីក្នុងលោក សម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ សម្តែងហើយ ក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។

**ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់ចាតុម្មហារាជ បានឮសំឡេងនៃភុម្មទេវតាទាំងឡាយហើយ ក៏ញុំាងសំឡេងឱ្យ លាន់ឮឡើង (ដោយសេចក្តី សរសើរដូចគ្នា) ។

**ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវតិំសា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្ស បានឮ សំឡេងនៃទេវតា

ក្នុងជាន់ចាតុម្មហារាជហើយ ក៏ញុំាងសំឡេង ឱ្យលាន់ឮឡើង ( ដោយសេចក្ដីសរសើរដូចគ្នា ) ។

**តាវត្តឹសានំ ទេវានំ សទ្ទំ សុត្វា យាមា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់យាមា បានឮសំឡេង នៃទេវតាក្នុងជាន់តាវត្តិង្ស ហើយក៏ញុំាងសំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្ដីសរសើរដូចគ្នា ) ។

**យាមានំ ទេវានំ សទ្ទំ សុត្វា តុសិតា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់តុសិត បានឮសំឡេង នៃទេវតា ក្នុងជាន់យាមា ហើយក៏ញុំាងសំឡេងឱ្យលាន់ឮឡើង ( ដោយសេចក្ដីសរសើរដូចគ្នា ) ។

**តុសិតានំ ទេវានំ សទ្ទំ សុត្វា និម្មានរតី ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់និម្មានរតី បានឮ សំឡេងនៃទេវតា ក្នុងជាន់ តុសិត ហើយ ក៏ញុំាងសំឡេងឱ្យលាន់ ឮឡើង (ដោយសេចក្ដី សរសើរដូចគ្នា ) ។

**និម្មានរតីនំ ទេវានំ សទ្ទំ សុត្វា បរនិម្មិតវសវត្តី ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់បរនិម្មិតវសវត្តី បានឮសំឡេងនៃទេវតា ក្នុងជាន់និម្មានរតីហើយ ក៏ញុំាងសំឡេង ឱ្យលាន់ឮឡើង ( ដោយសេចក្ដីសរសើរដូចគ្នា ) ។

បរនិម្មិតវសវត្តីនំ ទេវានំ សទ្ទំ សុត្វា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ទេវតាទាំងឡាយក្នុងពួកព្រហ្ម បានឮសំឡេងនៃ ទេវតាក្នុងជាន់ បរនិម្មិតវសវត្តីហើយ ក៏ញុំាងសំឡេង ឱ្យលាន់ឮ ឡើង ដូច្នេះថា ចក្រគឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែង ជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នក ឯណានីមួយក្តី ក្នុងលោកសម្តែងពុំបានឡើយ មានតែព្រះដ៏មាន ព្រះភាគ ព្រះអង្គត្រាស់ សម្តែងហើយ ក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។

ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ សំឡេងសាធុការលាន់ឮឡើង ទៅដរាបដល់ ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយអាការ លាន់ឮត១ គ្នា ដូច្នេះ ។

អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ ទាំងម៉ឺនលោកធាតុនេះ ក៏កក្រើកញាប់ញ័រទាំងខាងលើ ទាំងខាងក្រោម និងញាប់ញ័រក្នុងទិសទាំងពួង ។

អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្ម ទេវានំ ទេវានុភាវន្តិ ទាំងរស្មីដ៏រុងរឿងក្រៃពេក នឹង ប្រមាណមិនបាន កន្លងលើស ទេវានុភាព នៃទេវតាទាំងឡាយក៏កើតឡើង ប្រាកដក្នុងលោក។

អថខោ ភគវា ឧទានំ ឧទានេសិ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោតិ លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បន្លឺនូវឧទានវាចាថា ឱ ! កោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎ ឱ ! កោណ្ឌញ្ញៈ បានចេះដឹង ហើយហ្ន៎ ។

ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោ ត្វេវ នាមំ អហោសីតិ ព្រោះហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញៈ នេះឯង បានមកជាឈ្មោះនៃព្រះកោណ្ឌញ្ញៈដ៏មានអាយុ ។

**ព្រះធម្មចក្កប្បវត្តនសូត្រ ចប់**

# បាលីនមស្ការបូជាសត្តមហាឋាន

**បឋមំ ពោធិបល្លង្កំ　　ទុតិយំ អនិមិសកំ**

**តតិយំ ចង្កមំសេដ្ឋំ　　ចតុត្ថំ រតនឃរំ**

**បញ្ចមំ អជបាលញ្ច　　មុច្ចលិន្ទេនឆដ្ឋមំ**

**សត្តមំ រាជាយតនំ　　សត្តាហំ មុនិសេវិតំ**

**ឯតេ សត្តមហាឋានេ　　ជម្ពូទីបេ បតិដ្ឋិតា**

**បូជិតា នរទេវេហិ　　អហំ វន្ទាមិ ទូរតោ**

*ខ្ញុំសូមបង្គំប្រណម្យវន្ទា　　ឋានព្រះភគវ៉ានានាឆ្ងាយជិត*

*ឋានធំប្រាំពីរព្រះមុនីនៃបនិត្យ　　ឋានមួយទ្រង់ឋិតពិតមួយសប្តាហ៍ ។*

*សត្តមហាឋានមហាចេតិយ　　ពួកជនប្រុសស្រីគប្បីជ្រះថ្លា*

*ជាឋានបូជានៃមនុស្សទេវតា　　ឋិតនៅអស្ចារ្យក្នុងជម្ពូទ្វីប ។*

**បឋមំ ពោធិបល្លង្កំ**　　*ទ្រង់តាំងបធានគ្មានស្តាយជន្មជីព*

ត្រាស់ជាព្រះពុទ្ធដុតភ្លើងប្រទីប មនុស្សជម្ពូទ្វីបមានលាភថ្ងៃថ្លា ។

**ទុតិយំ អនិមិសកំ** ទ្រង់តាំងកាយឈរទិសបូពិឧត្តរា

នៃព្រះពោធិព្រឹក្សមិនព្រិចនេត្រា ទ្រង់ទតវិចារណ៍មហាឋានពុទ្ធោ។

**តតិយំ ចង្កមំ សេដ្ឋំ** ទ្រង់តាំងហឫទ័យក្នុងព្រៃព្រះពោធិ៍

ទ្រង់យាងទៅមកពីទីទ្រង់ឈរ និងគល់ព្រះពោធិ៍ប្រពៃអស្ចារ្យ ។

**ចតុត្ថំ រតនឃរំ** ទ្រង់តាំងពលំកម្លាំងប្រាជ្ញា

ព្រះជ្រែកអភិធម្មក្នុងផ្ទះរតនា ពាយព្យទិសានៃទីត្រាស់ដឹង ។

**បញ្ចមំ អជបាលញ្ច** ទ្រង់តាំងទ្រង់ដាក់ហឫទ័យនឹងធឹង

នៅទីទទួលបាយាសត្រាស់ដឹង ខាងកើតដងស្ទឹងនេរញ្ជរា ។

**មុច្ចលិន្ទនឆដ្ឋមំ** ទ្រង់តាំងបល្ល័ង្កគង់ក្នុងធម្មា

ខាងត្បូងព្រះពោធិ៍មាននាគរាជា បាំងព្រះភគវាការពារពិរុណ

**សត្តមំ រាជាយតនំ** ទ្រង់តាំងធម្ម៌ខ្លាំងក្លាដោយគុណ

ខាងត្បូងមុច្ចលិន្ទព្រះឥន្ទចុះមុន បូជាព្រះគុណគង់ក្រោមដើមកែស។

**សត្តមហាថានមហាះចេតិយ** សូត្ររៀងរាល់ថ្ងៃចម្រើនចំណោះ

ចម្រើនចិត្តស្ងប់រស់មិនប្រហែស កាត់បង់កិលេសមានះឫស្យា ។

ព្រះពុទ្ធត្រាស់ដឹងទីពឹងក្នុងលោក ផុតពីទុក្ខសោករាគរោគតណ្ហា

គង់ក្នុងឋានស្ងាត់ប្រាំពីរសប្តាហ៍ ចេតិយសម្មាសម្ពុទ្ធគ្រប់អង្គ ។

# ធម្មនិយាម ៣០ របស់ព្រះពុទ្ធ គ្រប់ព្រះអង្គ

សូមថ្វាយបង្គំប្រណម្យវន្ទា　　ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ　　សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា

មួយរញ្ជួយភពជាតិគ្រប់ចុងក្រោយ　　បារមីនាំឲ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា　　ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។

ពីរគឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌　　ស្មឹងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា　　ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។

បីថវិយាបថនៃព្រះមាតា　　ពេលគ្រប់មាសាសាស្ដាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ　　ប្រសូត្របុត្រថ្ងៃហឫទ័យជ្រះថ្លា។

បួនសួនឧទ្យានទីឋានប្រសូត្រ　　ក្នុងព្រៃរហូតឈើស្រូតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ　　ចក្រវាឡបព្វតាខ្ទរខ្ទារអ៊ូអរ ។

ប្រាំព្រះប្រសូត្រចុះស្រូតយាងឈាន　　ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រូតគ្រប់ទិសឋានក្លាហានបវរ　　ទើបបានបន្តបន្លឺសីហនាទ ។

ប្រាំមួយប្រមើលទតមើលនិមិត្ត　　ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត　　ចិត្តឥតរវាតយាត្រាសាងផ្នួស ។

ប្រាំពីរធិរោផ្តាច់ប្តូរព្យាយាម ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនិងបានត្រាស់ដឹង ។

ប្រាំបីមហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា។

ប្រាំបួនជូនភ័ព្វទ្រង់ទ្រាប់ស្បូវក្បាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា បល្ល័ង្កភគវាផុះគ្រាសាយ័ណ្ហ ។

ដប់គាប់ហឫទ័យអានាបាណៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនកាន់ ដំណើរជវនៃជាន់ធ្ងន់កាមា ។

ដប់មួយជំនួយពីព្រះបារមី ផ្ចាញ់មារអប្រិយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។

ដប់ពីរមុនីអង្គទ្រង់សម្រេចញាណ ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពីសាខបុណ្ណមីកើតញាណប្លែកៗ ពោធិញាណខ្ពស់ឯងកក្រើកធរណី។

ដប់បីក្សត្រថ្ងៃគង់ក្នុងមហាឋាន វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកស្តួយស្ថានទី ចេតិយព្រះមុនី ប្រាំពីរ កន្លែង ។

ដប់បួនជូនព្រហ្មជុំអារាធនា សូមព្រះភគវាយាងត្រាស់សម្តែង
ព្រះធម៌ប្រពៃវិស័យសូរ្យសែង ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ។

ដប់ប្រាំចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក ឥសិបតនៈព្រៃមិគទាយា

បានត្រៃរតនៈអាសាឡ្ហបូជា ថ្ងៃព្រះភគវាស្ដាបនាព្រះសង្ឃ ។

ដប់ប្រាំមួយទ្រង់គង់ត្រាស់ឱវាទ បាដិមោក្ខស្អាងស្អាតឱវាទផូរផង់

បេះដូងព្រះធម៌ពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។

ដប់ប្រាំពីរទ្រង់គង់វត្តជេតពន ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី

ទ្រង់យកអរុណជេតពនសួស្ដី ជេតពនជិតស្រីអាស្រ័យជានិច្ច ។

ដប់ប្រាំបីទ្រង់សម្ដែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច

នៅក្រុងសាវត្ថីប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា ។

ដប់ប្រាំបួនទ្រង់គង់បានត្រ័យត្រឹង្ស ត្រិះរិះរំពឹងថ្លឹងគុណមាតា

សម្ដែងអភិធម្មស្ដ័ក្កសមអស្ចារ្យ ថ្វាយព្រះមាតាសុខាអមតៈ ។

ម្ភៃគឺព្រះអង្គទ្រង់ចាកទេវលោក ស្ដេចយាងចុះមកដែនសង្កស្សៈ

មហាជនច្រើនពិតយកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ ។

ម្ភៃមួយគឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ៍

អរហត្តផលតម្កល់ប្រក្រតី ធាប់ក្ដីយូរក្ដីវិស័យពុទ្ធញាណ ។

ម្ភៃពីរប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យសព្វសត្វដែលមាន

ដោយព្រះករុណាសមាបត្តិញាណ ត្រួតសត្វកោដិលានមានពីរវារៈ។

ម្ភៃបីទ្រង់លៃវិន័យអាជ្ញា បញ្ញត្តសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក មានហេតុជាក់លាក់ទើបដាក់វិន័យ។

ម្ភៃបួនអង្រួនហឫទ័យករុណា ជាតកទេសនាសាស្តាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍ ។

ម្ភៃប្រាំទ្រង់ប្រោសដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។

ម្ភៃប្រាំមួយទ្រង់គង់ធ្ងន់ក្នុងធម៌ បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្តេចយាងទទួលស្រុះស្រួលដោយអង្គ គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌ ។

ម្ភៃប្រាំពីរទ្រង់គង់ចាំវស្សា បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ។

ម្ភៃប្រាំបីទ្រង់គង់យ៉ាងហ្មត់ចត់ មុនកត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចទ្រង់យាមទាំងអស់ ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា។

ម្ភៃប្រាំបួនទ្រង់គង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា សោយរសមំសាហឫទ័យបរិសុទ្ធ។

សាមសិបអវសានទ្រង់បានចូលឈាន មុននឹងនិព្វានឈានច្រើនបំផុត
ម្ភៃបួនសែនកោដិសមាបត្តិបរិសុទ្ធ រួចហើយទ្រង់ផុតរលត់សង្ខារ ។

អហ៊ីរខ្ញុំបង្គំវន្ទា ឆ្ពោះព្រះភគវាព្រះធម៌ថ្លៃថ្លា

ព្រមទាំងព្រះសង្ឃផូរផង់លីលា ចិន្តាលំអុតព្រះពុទ្ធនិយាម ។

សូមឲ្យសព្វសត្វបដិបត្តិតាមធម៌ សាសនាបវរល្អដូចព្រះនាម

អរហំសម្មាគ្មានការទាក់ទាម កិលេសរវាមរវាតសូន្យបង់ ។

សូមឲ្យសាសនាសម្មាសម្ពុទ្ធ បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចេរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា

សូមមនុស្សទេវតាមានការគោរព ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសំរេចដូចក្តីប្រាថ្នា អស់នូវតណ្ហាទុក្ខាចប់ហោង ។

# ឋានត្រៃរតនៈ

ក្រុងពារាណសីទឹកដីពោធិសត្វ ក្នុងសង្សារវដ្តបំពេញបារមី
ព្រះបាទព្រហ្មទត្តគ្រងដែនកាសី ព្រះពោធិសត្វថ្ងៃបួសជាតាបស។
ឥសិបតនៈព្រៃមិគទាយា ឋានព្រះភគវាគ្រប់អង្គទាំងអស់
សម្តែងធម្មចក្រប្រោសពួកតាបស អរិយមគ្គខ្ពង់ខ្ពស់បឋមទេសនា។
អាសាធបុណ្ណមីថ្ងៃកំណើតធម៌ ទេសនាបវរមជ្ឈិមាយាត្រា
ថ្ងៃខួបកំណើតព្រះធម្មទេសនា បរិស័ទជ្រះថ្លាថ្វាយផ្កាចេតិយ ។
អាសាធបុណ្ណមីថ្ងៃកំណើតសង្ឃ សរណៈពេញអង្គសង្ឃគម្រប់បី
ឋានត្រៃរតនៈក្នុងដែនកាសី អាសាធបុណ្ណមីអាសាឡ្ហបូជា ។
ចេតិយព្រះយសខ្ពស់ព្រោះសសរ យសបានស្តាប់ធម៌តលំដាប់គ្នា
ឯហិភិក្ខុដោយព្រះភគវា ព្រះយសបានជាសង្ឃព្រះអរហន្ត។
ហាសិបប្អូនអង្គសម្លាញ់ព្រះយស មកបួសទាំងអស់ព្រៃមិគទាយវន
ឋានត្រៃរតនៈឋានព្រះភគវន្ត ត្រាស់ប្រាប់អរហន្តចេញផ្សាយសាសនា។

ខ្ញុំថ្វាយបង្គំឋានត្រៃរតនៈ ដោយចិត្តស្មោះស្ម័គ្រនឹកព្រះសាស្តា

នឹកព្រះអរហន្តនឹកធម្មទេសនា ខ្ញុំសូមប្រាថ្នាផុតកាមលោកីយ ។

# ការក្រាបថ្វាយបង្គំទិសទាំង ៩

អហំ តាំងស្មារតី ឱនសិរសីថ្វាយបង្គំ

ព្រះពុទ្ធជាធំ គង់មជ្ឈិមជាកណ្ដាល ។

មានអង្គអរហន្ដា គង់ទិសាសព្វៗកាល

ព្រះទ័យត្រេកត្រអាល ប្រោសប្រទានធម៌ទេសនា

ព្រះសារីបុត្រចាំ គង់ខាងស្ដាំព្រះសាស្ដា

ព្រះអានន្ទបច្ឆិមា គង់ខាងក្រោយព្រះអង្គស្មោះ

ព្រះមោគ្គល្លានណា គង់ឧត្ដរាឆ្វេងចំពោះ

ព្រះកោណ្ឌញ្ញត្ថេរនោះ គង់ទិសបូព៌ចំព្រះភក្ត្រ ។

ព្រះគវម្បតិត្ថេរ គង់នៅឯពាយ័ព្យជាក់

ព្រះឧបលិត្ថេរ គង់និរតីនៃព្រះអង្គ ។

ព្រះកស្សបត្ថេរ　　គង់នៅឯអគ្នេយ៍ត្រង់

រាហុលបុត្រព្រះអង្គ　　គង់នៅត្រង់ទិសឦសាន ។

បើអ្នកណាបានដឹងយល់　　ព្រះពុទ្ធមង្គលគួរឲ្យបាន

ទន្ទេញទុកក្នុងប្រាណ　　ប្រឹងសិក្សាថ្វាយបង្គំ ។

មានបាលីលោកពោលថា　　បើនរណាខំផ្ចិតផ្ចង់

លំអុតលំឱនអង្គ　　កុំឲ្យបង់ធម៌ប្រពៃ ។

ជ្រះសោករោគាពាធ　　ឧត្បាតវេសវាងវៃ

ភន្ដកាំងភៀសភិតភ័យ　　ឥតមោះមៃមកបៀតបាន ។

សួស្ដីជ័យជម្នះ　　មានតេជះរក្សាប្រាណ

ឥតអ្វីមកបៀតបាន　　វៀងរួចដល់និព្វានហោង ។

# ព្រះធម៌ប្រាំបួនឋាន

ព្រះពុទ្ធឋិតឋានមជ្ឈឹម ព្រះសារីបុត្រទាទឹមគង់ទាក់សិនណា
ព្រះអានន្ទគង់បច្ចិមា ព្រះមោគលានណាគង់ទិសឧត្តរ
ព្រះកោណ្ឌញ្ញគង់ទិសបូព៌ា ព្រះគវម្បតីចរណាគង់ពាយព្យ៍
ព្រះឧបលីគង់រតីផ្ជាប់ អង្គព្រះកសប្បគង់អាគ្នេយ៍ឋាន
ព្រះរាហុលគង់ទិសឥសាន្ត គ្រប់ប្រាំបួនឋានជាទីបូជា
យើងខ្ញុំបង្គំវន្ទា សព្វទិសនានាសូមសុខសួស្តី
សូមឲ្យបំបាត់ទុកភ័យ ឧបខបចង្រៃកុំបៀតបៀនកាយ
តេជអំណាចខ្ញុំថ្វាយ បង្គំពីឆ្ងាយសូត្រសព្វវេលា
ខ្ញុំសូមផ្តាច់កម្មពារវេរា ទាន់ព្រះភគវាសេអាមេត្រី
ព្រះអង្គស្រង់សត្វក្នុងលោកិយ ដាក់សំពៅថ្មីដំកល់ថានសុខ
ជាថ្នល់ជាស្ពានទៅមុខ ដាក់ដល់ឋានសុខគឺនិព្វានហ្មង ។

# បារមី ៣០

១-ឥតិបិ ទានបារមី សម្បន្នោ សោ ភគវា ឥតិបិ ទានឧបបារមី សម្បន្នោ សោភគវា ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ ទានបារមី ទានឧបបារមី ទានបរមត្ថបារមីដូច្នេះផង ។*

២-ឥតិបិ សីលបារមី សម្បន្នោ សោ ភគវា ឥតិបិ សីលឧបបារមី សម្បន្នោ សោភគវា ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ សីលបារមី សីលឧបបារមីសីលបរមត្ថបារមីដូច្នេះផង ។*

៣-ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោ ភគវា ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោ ភគវា ឥតិបិ នេក្ខម្មបរមត្ថបារមី សម្បន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ*

*ព្រះអង្គបរិបូណ៌ដោយ នេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្មបរមត្ថបារមីដូច្នេះផង ។*

**៤-ឥតិបិ បញ្ញាបារមី សម្បន្នោ សោ ភគវា ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោភគវា ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ បញ្ញាបារមី បញ្ញាឧបបារមី បញ្ញាបរមត្ថបារមីដូច្នេះផង ។*

**៥-ឥតិបិ វីរិយបារមី សម្បន្នោ សោ ភគវា ឥតិបិ វីរិយឧបបារមី សម្បន្នោ សោ ភគវា ឥតិបិ វីរិយបរមត្ថបារមី សម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ វិរិបារមី វិរិយឧបបារមី វិរិយបរមត្ថបារមីដូច្នេះផង ។*

**៦-ឥតិបិ ខន្តិបារមី សម្បន្នោ សោ ភគវា ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោ ភគវា ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោ**

**ភកវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ ខន្តិបារមី ខន្តិឧបបារមី ខន្តិបរមត្ថបារមីដូច្នេះផង។*

**៧-ឥតិបិ សច្ចបារមី សម្បន្នោ សោ ភកវា ឥតិបិ សច្ចឧបបារមី សម្បន្នោ សោ ភគវា ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ សច្ចបារមី សច្ចឧបបារមី សច្ចបរមត្ថបារមីដូច្នេះផង ។*

**៨-ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោ ភកវា ឥតិបិ អធិដ្ឋានឧបបារមី សម្បន្នោ សោ ភកវា ឥតិបិ អធិដ្ឋានបរមត្ថបារមី សម្បន្នោ សោ ភកវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយអធិដ្ឋានបារមី អធិដ្ឋានឧបបារមី អធិដ្ឋានបរមត្ថបារមីដូច្នេះផង ។*

**៩-ឥតិបិ មេត្តាបារមី សម្បន្នោ សោ ភកវា ឥតិបិ មេត្តាឧបបារមី សម្បន្នោ សោ ភកវា ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោ**

**ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយមេត្តាបារមី មេត្តាឧបបារមី មេត្តាបរមត្ថបារមីដូច្នេះផង ។*

**១០-ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោ ភគវា ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោ ភគវា ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយឧបេក្ខាបារមី ឧបេក្ខាឧបបារមី ឧបេក្ខាបរមត្ថបារមីដូច្នេះផង ។*

**១-ឥតិបិ សមតឹសបារមី សម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយ បារមីទាំង ៣០ ដូច្នេះផង ។*

# សេចក្តីត្រិះរិះរបស់នាងសិភាទិសាខា

**សេចក្តីត្រិះរិះរបស់ខ្ញុំថា** *តើនៅពេលណាខ្ញុំបានថ្វាយទាន*

*នូវប្រាសាទថ្មីតាមទ្រព្យដែលមាន* *ជាវិហារទានថ្វាយចំពោះសង្ឃ ។*

**សេចក្តីត្រិះរិះរបស់ខ្ញុំថា** *តើនៅពេលណាខ្ញុំបានឱនអង្គ*

*ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់* *ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត ។*

**សេចក្តីត្រិះរិះរបស់ខ្ញុំថា** *តើនៅពេលណាខ្ញុំបានថ្វាយកត្ត*

*ផ្សំដោយមំសៈធ្វើដោយហ្មត់ចត់* *សាលាកកត្តជាអាហារទាន ។*

**សេចក្តីត្រិះរិះរបស់ខ្ញុំថា** *តើនៅពេលណាជួបព្រះទ្រង់ញាណ*

*ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន* *ថ្វាយចីវរទានសំពត់សាច់ល្អ ។*

**សេចក្តីត្រិះរិះរបស់ខ្ញុំថា** *តើនៅពេលណាជួបសង្ឃបវរ*

*ថ្វាយភេជ្ជៈទឹកឃ្មុំប្រេងស្ករ* *ទឹកដោះគោល្អ និងទឹកអំពៅ ។*

**មកដល់ឥឡូវខ្ញុំបានសំរេច** *គ្រប់មុខស្រេចបាច់ឥតមានសល់នៅ*

*ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ* *ក្នុងដំណើរទៅកាន់ព្រះនិព្វាន ។*

# ធម៌ឧទ្ទិសផល

ទានសិលដែលខ្ញុំបានធ្វើហើយ　　ព្រះគុណស្តីយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា　　ជូនមាតាបិតាខ្ញុំ ។
ជីដូនទិងជីតា　　គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្ត គ្រប់និគម　　មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ　　នូវអំពើជាកុសល
សូមទានឲ្យបានដល់　　ទោះមណ្ឌលឆ្ងាយយ៉ាងណា។
កុសលទាំងអស់ហ្នឹង　　សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា　　នាំផល្លាទាំងអស់នេះ ។
ទៅជូនឲ្យខ្ញុំផង　　ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណេះ　　មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ　　ដោយសប្បាយទទួលយក

កូនចៅបានលៃលក បញ្ជូនមកគ្រប់ៗគ្នា ។

ដើម្បីសោយកម្សាន្ត សូមឲ្យបាននៅសុខជា

កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ។

##ធម៌ឧទ្ទិសសង្ខេប

ទានសិលយើងទាំងឡាយ សូមផ្សព្វផ្សាយដល់ញាតិមិត្ត

ទៅកាន់ទិព្វឋាយជិត មានវិបត្តិយ៉ាងណាក្តី

សូមឲ្យរួចរំដោះ ចាកទុក្ខទោសគ្រោះចង្រៃ

បានសុខរៀងរាល់ថ្ងៃ ជរាបដល់និព្វានហោង ។

## ធម៌សម្រាប់សូត្រឧទ្ទិស

សូមឲ្យអ្នកទាំងឡាយ សុខសប្បាយទាំងអស់គ្នា

កុំឲ្យមានរោគា ព្រមទាំងញាតិមិត្តសន្តាន

ចូរខំប្រឹងប្រព្រឹត្ត សាងសុចរិតធម៌ឲ្យបាន

សព្វថ្ងៃសាសនាមាន　　ខំធ្វើទានសីលភាវនា ។
កើតមកក្នុងលោកិយ　　ទាំងប្រុសស្រីមានវាសនា
ខំប្រឹងរៀនធម៌អាថ៌　　ទាន់សាសនាព្រះទ្រង់ញាណ
ដ្បិតយើងមិនដឹងផ្លូវ　　នឹងដើរទៅកាន់និព្វាន
ជាទីសុខក្សេមក្សាន្ត　　លះបង់បានចាកមន្ទិល ។
ជាធម៌ប្រពៃពិត　　វិសេសពិតនោះឯងណា
កាត់បង់នូវអវិជ្ជា　　គឺបណ្ដាញកិលេសហោង ។

# ផ្សាយមេត្តាចំពោះទិសទាំង១០

**១-សព្វេ បុរត្ថិមាយ ទិសាយសត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិសខាងកើត កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**២-សព្វេ បុរត្ថិមាយ អនុទិសាយសត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិសអគ្នេយ៍ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៣-សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិសខាងត្បូង កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៤-សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិសនិរតី កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៥-សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិសខាងលិច កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៦-សព្វេ បច្ចិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិសពាយ័ព្យ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៧-សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងជើង កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៨-សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅ ក្នុងទិស ឦសាន កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**៩-សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងលើ កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**១០-សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងក្រោម កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។**

សត្វទាំងឡាយទាំងពួង ចូរកុំមានពៀរនឹងគ្នា ចូរនូវជាសុខចុះ ចូរកុំមានទុក្ខនឹងគ្នា ចូរកុំមានព្យាបាទនឹងគ្នា ចូរឲ្យជាអ្នកឥតមានសេចក្តីទុក្ខភ័យ ចូរឲ្យមានអាយុវែង ចូរកុំឲ្យមានរោគ ចូរឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ចូររក្សាខ្លួនឲ្យបានសេចក្តីសុខចុះ ៗ

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**
**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ**

សត្វទាំងឡាយទាំងពួងដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅហោង ៗ

# គាថាសូមសេចក្តីសុខ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចីរំ រក្ខន្តុ សាសនំ ។**

*វីទេវតានិងនាគ ឋិតនូវភាគភូមិផែនដី ឬ លើអាកាសក្តី មាន សេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំហើយសូម ជួយថែទាំ ពុទ្ធសាសនាអស់កាលវែង ។*

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចីរំ រក្ខន្តុ រាជានោ ។**

*វីទេវតានិងនាគ ឋិតនូវភាគភូមិផែនដី ឬ លើអាកាសក្តី មាន សេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំហើយសូម ជួយថែទាំ ព្រះមហាក្សត្រអស់កាលវែង ។*

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតិយោ ។**

រីទេវតានិងនាគ ឋិតនូវភាគភូមិផែនដី ឬ លើអាកាសក្តី មាន

សេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំហើយសូម

ជួយថែទាំ ក្រុមញាតិអស់កាលវែង ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតកេ ។**

រីទេវតានិងនាគ ឋិតនូវភាគភូមិផែនដី ឬ លើអាកាសក្តី មាន

សេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំហើយសូម

ជួយថែទាំ នូវពួកសត្វអស់កាលវែង ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ពាណិនោ ។**

រីទេវតានិងនាគ ឋិតនូវភាគភូមិផែនដី ឬ លើអាកាសក្តី មាន

សេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំហើយសូម

ជួយថែទាំ នូវយើងខ្ញុំអស់កាលវែង។